# ការសម្ភាសន៍របស់ អ៊ុំ យ៉ន់ យ៉ាន

**កៈ អ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណនរិទ្ធ          ខៈ អ្នកត្រូវគេសម្ភាសន៍ឈ្មោះយ៉ន់ យ៉ាន**

## ពត៌មានសង្ខេបរបស់ អ៊ុំស្រី យ៉ន់ យ៉ាន

សព្វថ្ងៃនេះអ៊ុំស្រីយ៉ន់ យ៉ានមានអាយុ៦៥ឆ្នាំហើយ គាត់កើតនៅឆ្នាំរការ ខែអស្សុជ ថ្ងៃសៅរ៍។ គាត់មានបងប្អូនទាំងអស់៥នាក់ ហើយគាត់ជាកូនបងគេបង្អស់ក្នុងគ្រួសារគាត់។ ក្រោយគាត់កើតបានប្រហែលជា៣ថ្ងៃ ឪពុករបស់គាត់បានលះលែងគ្នាជាមួយម្ដាយរបស់គាត់ ក្រោយមកម្ដាយរបស់គាត់បានមានស្វាមីមួយទៀត។

កៈ បាទជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ុំដែលបានឲ្យខ្ញុំសម្ភាសន៍ពីប្រវិត្តរបស់អ៊ុំ ហើយការសម្ភាសន៍ណឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថាព្រីហាំយ៉ង់ដែលនៅឯសហរដ្ឋអាមេរិក។ បាទ គោលបំណងរបស់សាកលវិទ្យាល័យគឺចង់សម្ភាសន៍ប្រវិត្តប្រជាជនខ្មែរ ដើម្បីរក្សារទុកប្រវិត្តប្រជាជនខ្មែរដើម្បីឲ្យកូនចៅជំនាន់ក្រោយរបស់អ៊ុំអាចស្គាល់ពីប្រវិត្តរបស់ជីដូនជីតាហើយរៀនអំពីប្រវិត្តរបស់ពួកគាត់ណាអ៊ុំ បាទហើយចឹងនៅពេលដែលខ្ញុំសម្ភាសន៍អ៊ុំចប់ ខ្ញុំនឹងដាក់ការសម្ភាសន៍របស់អ៊ុំណឹងនៅក្នុងវេបសារបស់សាលាដែលមានឈ្មោះថា www.cambodianoralhistoryproject.byu.edu ណាអ៊ុំ ចឹងតើអ៊ុំយល់ព្រមឲ្យខ្ញុំដាក់សម្ភាសន៍របស់អ៊ុំចូលទៅក្នុងវេបសាយរបស់សាលាទេអ៊ុំ?

ខៈ ចាស យល់ព្រមតើ។

កៈ បាទសម្រាប់ថ្ងៃខែដែលខ្ញុំសម្ភាសន៍អ៊ុំនេះគឺ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ ហើយការសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិចុងឃ្មៀស ឃុំចុងឃ្មៀស ក្រុងសៀមរាប ខេត្តសៀមរាប ណាអ៊ុំណា ហើយខ្ញុំជាអ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណនរិទ្ធ អញ្ចឹងខ្ញុំចង់សួរថាតើអ៊ុំមានឈ្មោះពេញឈ្មោះអ្វីដែរអ៊ុំ?

ខៈ ខ្ញុំឈ្មោះអញ្ចឹងឯង ឈ្មោះយ៉ន់ យ៉ាន។

កៈ យ៉ន់ យ៉ាន?

ខៈ ចាស។

កៈ បាទ ចុះអ៊ុំមានឈ្មោះហៅក្រៅទេអ៊ុំ?

ខៈ អត់ទេ តាមតែគេអ្នកហៅនោះពីដើមមិញយូរហើយវាបាត់ហើយមនុស្សងាប់បាត់ហើអ្នកហៅខ្ញុំថាអ៊ុំម៉ាប់ អ៊ុំម៉ាប់នោះ

កៈ ចុះអ៊ុំមានអាយុប៉ុន្មានហើយឆ្នាំនេះ?

ខៈ ខ្ញុំ៦៥ឆ្នាំហើយកូន។

កៈ ចុះអ៊ុំចាំថ្ងៃខែឆ្នាំកំណើតអ៊ុំបានទេអ៊ុំ?

ខៈ ចាំទាំងអស់។

កៈ បាទអាចប្រាប់បន្តិចបានទេអ៊ុំ?

ខៈ ឆ្នាំរការ ខែអស្សុជ ថ្ងៃសៅរ៍។

កៈ ចុះឆ្នាំបារាំងវិញអ៊ុំចាំទេអ៊ុំ?

ខៈ អត់ ទទេអត់ដឹង។

កៈ ចុះអ៊ុំមានស្រុកកំណើតនៅឯណាដែរអ៊ុំ?

ខៈ ស្រុកកំណើតខាងឪពុកខ្ញុំនៅនេះឯងតែខាងម្តាយនៅបាត់ដំបង។

កៈ បាទអញ្ចឹងអ៊ុំកើតមកនៅបាត់ដំបងមែនអ៊ុំ?

ខៈ ចាស កើតនៅបាត់ដំបងតែខ្ញុំមកនៅស្រុកនេះយូរណាស់ទាល់តែអាពតនេះបានគជម្លៀសទៅបានខ្ញុំនៅបាត់ដំបង អញ្ចឹងទៅវិញខ្ញុំរត់ពីខាងណេះនោះចុះខាងណេះអត់បាយកូន បើនិយាយទៅខ្ញុំរត់តាំងពីសម័យលន់ នល់នេះដែលទម្លាក់គ្រាប់បែកខ្លាំងណាកូនខ្ញុំរត់ទៅនៅព្រែកទាល់ដល់ចេញពីព្រែកទាល់ណឹងដែលគេជម្លៀសទៅបានទៅនៅមុខដំបូនៅបាក់អង្រែកហើយគេជម្លៀងសមកវិញមកព្រែកទាល់វិញទៅចុងក្រោយទៀតបានគេជម្លៀសឯខាងពោធិសាត់នោះប៉ុន្តែខ្ញុំអត់ទៅទេខ្ញុំរត់ទៅទៅពួននិងព្រែកនរិន្ទ ទៅបានធ្លាក់ទៅដល់អូរតាគីអូរតាកែនោះណាកូន ខ្ញុំនេះវែងឆ្ងាយណាស់បើនៅព្រែកទាល់នេះគេចាប់យកទៅចង់សម្លាប់២ ៣ដងគេថាមានមាស២គីឡូទៅគេចាប់ម្តងហើយយើងគេថាខ្ញុំណឹងដូចថា បញ្ចុះបញ្ចូលនារីយុវជនឲ្យស្រលាញ់គ្នាប៉ុនអត់ដឹងសោះ អត់ដឹងខ្យល់គេចាប់ខ្ញុំយកទៅបាញ់ចោលប្រុងយកទៅបាញ់ចោលក៏មេឃធ្លាក់ភ្លៀងទៅប្តីខ្ញុំទៅសំពះអង្វរម៉េចទេទេវតាជួយទៅខ្ញុំអំពើគ្រង់បានខ្ញុំរស់ មួយលើក ពីរលើកនៅបាក់អង្រែកក៏ចឹងដែរ អូ!ច្រើនណាស់កូនវេទនារាប់មិនអស់។

កៈ អាយុប៉ុន្មានអ៊ុំមកពីបាត់ដំបងមកនៅនេះ?

ខ៖ ខ្ញុំមកពីបាត់ដំបងខ្ញុំមកនៅឯណោះខ្ញុំអាយុប្រហែលជា៤០ជាង ប្រហែល៤០តិចតួចទេ។

ក៖ បាទអ៊ុំនៅបាត់ដំបងណឹងខាងណាដែរអ៊ុំកាលណឹង?

ខ៖ កាលណឹងមុនដំបូងខ្ញុំនៅភូមិព្រៃកទាល់ ខេត្តបាត់ដំបង ស្រុកឯកភ្នំដូចគ្នាឃុំដោះជីវាំង ដល់ពេលខ្ញុំឡើងទៅនៅបាត់ដំបងខ្ញុំនៅសាលាតាអន នៅសាលាតាអនស្រុកអឺ ស្រុកឯកភ្នំ ដូចគ្នាតែភូមិព្រៃកកញ្ជ្រែង ឃុំព្រៃកនរិន្ទ ហើយកូនខ្ញុំកើតរដិ កូនកើតតាម ចាំមើលកើតអាបង ទីមួយណឹងកើតសាលាតាអន មីស្រីកតើបាក់ព្រារ អាពីរណឹងកើតព្រៃកទាល់ កើតនៅជ្រៃ អូៗ រាប់មិនអស់ម្ដាយវេទនាណាស់កូនប្រុស វេទនាថារកអីប្រៀបមិនបានថាខ្ញុំយំស្រែកលែងយំ លែងចេញ ខ្ញុំនិយាយពីប្រវិត្តខ្ញុំខ្ញុំក្រណាស់ខ្ញុំវេទនាណាស់ ខ្ញុំប្រាប់ត្រង់នេះខ្ញុំអត់មានត្អូញត្អែរ ថាខ្លួនឯងគ្រាន់បើហើយចេះតែមកត្អូញត្អែរឲ្យគេអាណិតស្រណោះមិនមែនទេកូនប្រុសម្ដុយ មែន ខ្ញុំនិយាយនេះនិយាយដោយការពិតត្រង់។

ក៖ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ ខ្ញុំបើនិយាយទៅ ចំណែកខ្ញុំនេះតែម្នាក់ឯងទេតែកូនប្ដីក្រោយ៤ ខ្ញុំនិយាយនេះនិយាយត្រង់។

ក៖ ចុះបងប្អូនអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរបងប្អូនអ៊ុំ?

ខ៖ ៥នាក់។

ក៖ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំទី១ ។

ក៖ កូនបងគេ?

ខ៖ ចាស។

ក៖ ហើយចុះអ៊ុំអាចរៀបរាប់ប្រាប់ឈ្មោះបងប្អូនទាំងអស់របស់អ៊ុំបានទេ ពីបងគេរហូតដល់ពៅគេណាអ៊ុំ?

ខ៖ ចាសបានតើកូន បងទី២ឈ្មោះហ៊ុន ទី៣ឈ្មោះហ្សូរ ទី៤ឈ្មោះកាំង ទី៥ឈ្មោះពៅ។

ក៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មានដែរអ៊ុំ?

ខ៖ ស្រី ប្រុស១ ស្រី៤។

ក៖ អរ ប្រុស១ ស្រី៤?

ខ៖ ចាស។

ក៖ បាទអ៊ុំ ចុះអ៊ុំអាចប្រាប់បន្ថិបានទេថាកាលពីនៅក្មេង អ៊ុំធ្លាប់ធ្វើអ្វីខ្លះដែរជាមួយបងប្អូន ឬក៏មានអនុស្សាវរីយ៍អ្វីដែលជាមួយគ្នាអ៊ុំ?។

ខ៖ អូនអើយវេទនាណាស់ ធ្លាប់និយាយទៅបើជីវិតអ្នកក្រវិញគ្មានអ្នកណាថាដល់ខ្ញុំទេ តាំងពីម៉ែដល់កូនទៀត ក្រនោះវេទនានោះដើរនៅរសាត់រសាយអត់ឃ្លានថាវេទនានៅក្នុងព្រៃ បាចត្រីបាចអីមិនដឹងថារាប់រៀបមិនអស់ណាកូនបើសិនជាដាក់រឿងវិញខ្ញុំប្រាប់មិនដឹងប៉ុន្មានភាគទេរឿងខ្ញុំ វេទនាណាស់អូនអើយខ្ញុំក្រណាស់ខ្ញុំនិយាយតាមត្រង់ ម៉ានិយាយទៅពូជអំបូរគមានតែក្រតែពោះរម៉ែយើងមួយណឹងដូចថាបងប្អូនគេខឹងបានប្ដីអ្នកក្រទៅគេអត់រាប់រកទេ បងប្អូនខាងម្ដាយខ្ញុំគាត់អត់រាប់រកបងប្អូនគាត់មានតើ ទៅគេមិនរាប់មិនរកទេចំការក្រូចគេល្ងឹងគេខឹងគេថាយើងបានប្ដីអ្នកក្រទៅប្ដីក៏អត់ចេះរកអីអត់សូវចេះរកអីណា ចុះគាត់មិនសូវចេះរកអីទៅក៏ដូចថាគេខឹងទៅមិនសូវរាប់អានយើង ខាងឪពុកក៏គាត់មិនសូវរាប់អានគាត់ស្អប់ គាត់ខឹង។

ក៖ បាទអ៊ុំ ចុះបងប្អូនរបស់អ៊ុំទាំង៩នាក់ទៀតសព្វថ្ងៃនៅឯណាដែរអ៊ុំ?

ខ៖ នេះជុំនេះឯងកូនៅជុំគ្នាទាំងអស់គ្នានោះតូបៗនោះឯង ដែលខ្ញុំនេះដីនេះក៏មិនមែនដីខ្លួននេះដែរដីដែលគេចែកឃុំចែកទេនេះៗ ខ្ញុំនេះមិនមែនដីទិញខ្លួនឯងអីទេដីកន្លែងឃុំកន្លែងភូមិគេចែកណឹងឯង ទៅអង្គរធ្វើផ្ទះឲ្យកាលនោះខ្ញុំថាទៅទិញដីនៅស្រែកណ្ដាលទៅចាក់ដីគេនោះកាលនោះមួយឡាវ៉៩ ១០រៀល ១០រៀលទៅគេឲ្យចាប់ ដល់គេឲ្យចាប់ទៅកូនអើយ ខ្ញុំឈឺសឹងងាប់ស្មារទោសគ្មាន ស្មានតែគ្មានជីវិតមកមានថ្ងៃនេះទេ ស្មានតែងាប់ហើយ ចាញ់នោះចាញ់បើប្ដីខ្ញុំស្មារទោស ភ្នែកឡើងជម្រៅចង់មួយចង្អុលដៃហើយខ្ញុំនេះក៏ដោយ មានអ្នកណាសង្ឃឹមថារស់ខ្ញុំក៏មកវិញ ក៏ចោលដីចោលធ្លីនៅឯណោះឯងចោលទាំងអស់ទៅគេយកអស់ហើយមានអ្នកណាបានមកវិញទៅក៏បានគុណបុណ្យមេភូមិស៊ុនណឹងឯងគាត់ចែកដីមួយឡ គេលក់អស់គ្រប់គ្នាខ្ញុំអត់លក់ប្ដីខ្ញុំគាត់អត់លក់ទេថាលក់ធ្វើអីខ្លាចយើងមកនៅយើងអត់យើងមកព្រោះយើងធ្លាប់អត់ ខ្ញុំវេទនាណាស់អូនខ្ញុំនិយាយប្រាប់ត្រង់ខ្ញុំមិនមែនថានេះទេ ខ្ញុំបានរស់សព្វថ្ងៃនេះខ្ញុំសរសើរខ្លួនខ្ញុំបានគ្រាន់ហើយពីដើមមិញខ្ញុំប្រាប់ទៅវេទនាម៉ែឪសំឡុយកាត់ជា២ កាត់តវគ្គាដូចយើងស្អីចឹងណាកូនខ្ញុំនិយាយតាមត្រង់ខ្លួនខ្ញុំផ្ទាល់ ខ្ញុំអត់។

ក៖ បាទអ៊ុំ ចុះកាលសម័យប៉ុល ពតអ៊ុំមានអាយុប៉ុន្មានឆ្នាំហើយអ៊ុំ?

ខ៖ ខ្ញុំកាលសម័យចូលភ្លាមឆ្នាំ៧៥ខ្ញុំអា១៩ឆ្នាំ ១៩ដល់កូនឯងគិតមើលឡើងចប់ គិតមើល១៩ ២០រ៉ា៧៦ ៧៧ ២២មែន ចឹងឯង២២ ៧៨ ២៣ ៧៩ ២៤ ដល់ចប់ ខ្ញុំចាប់ពីណឹមកគឺ ចល័តជម្លៀសទៅ ជម្លៀសមក ជម្លៀសទៅ ជម្លៀសមកសឹងតែនិងងាប់និងរស់ មិននឹកស្មានថាបានប៉ុណ្ណេះទេ បានរស់ដល់ប៉ុណ្ណេះទេខ្ញុំ។

កៈ ប៉ុន្តែអ៊ុំអាចប្រាប់បន្តិចបានថាពីមុន អ៊ុំបាននិយាយថាពីមុនសម័យលន់ នល់ណឹងគេទម្លាក់គ្រាប់មែនទេអ៊ុំ?

ខៈ ចាស ចាសទម្លាក់មែន។

កៈ អ៊ុំអាចនិយាយប្រាប់បានទេថាកាលណឹងម៉េចដែរអ៊ុំ?

ខៈ កូនទម្លាក់ណាប្រជាជននៅនេះណារត់ចូលក្នុងរូង មីងខ្ញុំត្រូវជាមីងខាងឪពុកចុងខ្ញុំងាប់ក្នុងរូងភ្នំណឹងឯង កំពុងមានផើមចុះគេបាញ់មកកូនអើយជំនាន់លន់ នល់នោះ រត់ទាន់ទាន់ រត់មិនទាន់ក៏ងាប់ទៅ ខ្ញុំកាលជំនាន់ណឹងខ្ញុំអត់ដែលខែនេះខ្ញុំអត់បាននៅនេះទេខ្ញុំទៅនៅគេហៅចំការតាម៉ៅនោះកូន ចំការតាម៉ៅណឹងក្រោមនិយាយទៅ ក្រោយកន្ទាយគោមហួសទៅនោះតិចណា ពីដើមមិញព្រៃធំៗគេមិនបស់ផ្ទះណឹងដល់ពេលទម្លាក់គ្រាប់បែកកូនអើយប្រហុកយើងពីដើមមិញគេដាក់ឡាំងប៉ុនៗនេះខ្ទាយនៅលើដំបូងផ្ទះ ទៅក៏នាំគ្នារត់អ៊ុំខ្ញុំម៉ែខ្ញុំរត់ទៅកំពង់ភ្លុករត់ទៅដល់គេទម្លាក់ឯណោះទៀតបកមកនេះ មកទៅនៅឯជ្រៃទៅនៅជ្រៃគេទម្លាក់នៅជ្រៃទៀត ទម្លាក់នៅជ្រៃហើយបានចូលដល់ព្រែកទាល់ណឹង បានគេចេញវាយទៅបានទៅដល់ព្រែកទាល់បានសុខណឹងឯងអត់បានទម្លាក់ទេ ទៅបាញ់ឯកំពង់ប្រហុកកំពង់អីតែភូមិព្រែកទាល់ណឹងអត់បាញ់ទេ។

កៈ ចុះកាលដែលអាពតចូលមកណឹងអ៊ុំនៅបាត់ដំបង ឬក៏នៅសៀមរាប?

ខៈ អត់ទេខ្ញុំនៅឯព្រែកទាល់ណឹងឯងកូនដែលរត់ពីនេះទៅនៅឯព្រែកទាល់ណឹងឯង ចាស នៅភូមិព្រែកទាល់ណឹងឯង តាបើនិយាយទៅវាខេត្តបាត់ដំបង ភូមិព្រែកទាល់នោះណាកូន។

កៈ អ៊ុំអាចប្រាប់ ឬក៏អ៊ុំនៅចាំទេថាចូលពតចូលមកណឹងគេដំបូងគេឲ្យធ្វើអីខ្លះ? ហើយគេជម្លៀសអ៊ុំទៅណាខ្លះៗដែរអ៊ុំ?

ខៈ មកដល់ភ្លាមអត់មានឲ្យធ្វើអីទេហៅប្រជុំបានជម្លៀសឡើងទៅបាកអង្រែកគេហៅបាក់អង្រែកណាកូន វត្តបាក់អង្រែកណឹងគេឲ្យទៅកូនអើយបន្តគ្នាទូកចតបន្តគ្នាក្រមុំកំលោះអីណាគេម៉ែឪណឹងចេះតែខ្សិបគ្នាគេយកយើងនៅនេះទៅនោះទៅណាប្រាប់គ្មីប្រាប់គ្នាក៏តាំងដើរនិយាយទៅដូចតទិញបន្លែចឹងឯង ខ្សិបខ្សាឲ្យកូនរៀបបានគ្នា អរនេះខ្សិបខ្សារក៏បានគ្នាអ្នកណាយកក៏យកអ្នកណាមិនបានយកក៏គេចាត់ចូលខាងនារីចូលខាងនារី ខ្ញុំនេះកុហកគេថាមេម៉ាយម៉ែខ្ញុំកុហកថាមេម៉ាយ ថាកូនខ្ញុំមេម៉ាយទេប្តីវាបែកគ្នាថាប្តីវាកុហកគេថាប្តីវាទៅសៀមរាប ចឹងដល់ពេលអញ្ចឹងទៅបានខ្ញុំរួចខ្លួនទៅបានមកដល់ មកដល់ព្រែកទាល់គេជម្លៀសទៅអញ្ចេះទៅ គេជម្លៀសមកវិញគេយក៨០គ្រួសារយកបកមកភូមិព្រែកទាល់វិញ

បានខ្ញុំគេឲ្យចូលស្ទីគេហៅស្ទីមេម៉ាយនោះគេហៅស្ទីនារីអីទេភ្លេចទៅបាត់ហើយខ្ញុំ នារីអីទេគេឲ្យចូលជាមួយគេណឹងខ្ញុំភ្លេចបាត់ ចូលទៅយើងមេម៉ាយគេហៅនារី។

ក៖ ឈានមុខ?

ខ៖ ទេ បើនារីគេនោះគេហៅនារីដាច់ខាតគេផ្សេង យើងម៉េម៉ាយគេឲ្យនៅក្រោយបន្ទាប់គ្នាណាកូន អញ្ចឹងឯងតែខ្ញុំណឹងកាលណឹងម៉ែខ្ញុំគាត់កុហកសូម្បីតែប្អូនខ្ញុំក៏ម៉ែខ្ញុំកុហកថាឆ្កួត ប្រពន្ធពូពន់នេះមិនម៉ែខ្ញុំកុហកអាពតថាកូនខ្ញុំឆ្កួតជ្រូកជាន់អីចេះតែប្រាប់ទៅ ហើយវាណឹងក៏ចឹងទៅចេះតែកុហកគេ។

ក៖ បាទអ៊ុំ ចុះហើយកាលជម្លៀសណឹងធ្វើការងារម៉េចខ្លះដែរអ៊ុំ? វាឲ្យធ្វើអ្វីខ្លះដែរហើយការហូបចុកណឹងយ៉ាងម៉េចដែរអ៊ុំ?

ខ៖ បើនៅឯទន្លេនេះកូនខែប្រាំងបាយ បាយគេហៅបាយចំហុយគេនោះដូចបបរចឹងណាងតែគេចែក ដូចថាមនុស្សន្នានទៅគេចែកតែអ្នកទៅគេឲ្យហូបមួយចម្អែត តែដល់ពេលទៅលើគេហៅភូមិបាក់អង្រែកណឹងមួយកំប៉ុង មុនដំបូង៣កំប៉ុង១ខ្វះហើយលាយត្រកួនទឹកឡើងខ្មៅស្មារទោសដូចចែកគ្នា៩ ១០នាក់ចឹងកូនអើយមួយធុងប៉ុណ្ណេះនេះសំរិតទៅបានអង្ករមួយវែកផុតពីនោះត្រកួនទឹកណឹងឯង ទឹកឡើងខ្មៅចុះត្រកួនតាមវាលនោះ ហើយការងារបើនៅឯទន្លេនេះគេឲ្យធ្វើត្រីទាំងយប់ទាំងថ្ងៃប្រុសធ្វើតាមប្រុសទៅ ស្រីធ្វើតាមស្រីទៅណាហើយគេថាមុខសញ្ញាគេនោះគេឲ្យទៅមុខសញ្ញាខាងត្រី ខាងបោកឃ្មុំខាងទៅគេហៅមោងកង្ហារគ្រប់កន្លែងតែបើស្រីៗគេឲ្យលីសែងសរសៃខ្វីណាកូនឡើងប៉ុនៗនេះ ប៉ុនៗនេះឲ្យយើងសែងខ្ញុំណាស្មារទោសមិនណានិយាយនិងអូនឯង ទាស់ រាគ រាគឡើងស្មារទោសតែថ្ងៃស្មារនេះអាចម៍ដើរហូរតាមកែង កុំឲ្យបានគុណបុណ្យគេអុជទេកុំអីមិនមែនបានប៉ុណ្ណេះទេ បើយើងមិនធ្វើហើយសែមកហើយមិនមែនឲ្យយើងចាក់អញ្ចេះទេណាកូនគេឲ្យយើងគ្រវី គ្រវីចាក់ ចាក់ចូលឡើងប៉ុនៗនេះកូនគេឲ្យគ្រវីធ្វើម៉េចឲ្យក្រឡាប់ ឲ្យចាក់ភ្លឹបៗគេក្មេងៗគេធ្វើបានវាជរៗចឹងឯងអាខ្លះថាជរក៏បានចុះខ្លាចងាប់នោះ ខ្លះក្រមុំធ្លាក់ស្បូនណាខ្ញុំនិយាយណាជំនាន់ណឹងណា នេះភូមិព្រែកទាល់បើមិនជឿទៅសួរទៅអ្នកដែលនៅចំណាស់ៗអី សួរទៅសុទ្ធតែក្រមុំធ្លាក់ស្បូននោះឯងអ្នកមកពីលើភ្នំពេញអីណឹងគ្នាខ្លាចងាប់មកដល់ហែកត្រីឆៅស៊ីនោះដែលខ្ញុំមិនខ្លាចហា បានថាវេទនាណាស់ខ្ញុំ បើ១លើក ២លើកជម្លៀសទៅជម្លៀសមក ជម្លៀសទៅជម្លៀសមករត់ទៅឯណាឯណីដល់ឆ្នាំ៧៨បានគេទៅខាងពោធិសាត់ខ្ញុំទៅខាងនេះ ខ្ញុំទៅខ្ញុំចូលព្រែកនរិន្ទបានគេជម្លៀសខ្ញុំទៅខាងអូរតាគី អូរតាកែនោះវិញ។

ក៖ ចុះទៅខាងអូរតាគីណឹងធ្វើស្រែមែនអ៊ុំ?

ខ៖ ធ្វើស្រែ ប៉ុន្តែកូនអើយគេដាំបាយលាយសណ្តែកបាយអ្នកពោគមិនត្រូវគ្មានស៊ីកើតទេពាគនោះពាគគ្មានថ្ងៃឈប់ទេខ្ញុំ ហូរអាចម៍ដូចនេះហើយពេលថ្ងៃឡើងចេះគេឲ្យដូចថាយើងនៅឯភូមិចេះថ្ងៃឡើងគេឲ្យដើរទៅចុះតាមផ្លូវវាលទ្រាណាអូនស្គាល់វាលទ្រាអត់ វាលទ្រាណឹងចុះទៅកូនអើយឃើញតែមនុស្សគេសែងងាប់នោះងាប់ទៅព្រឹកណាថាមិនងាប់ ៣ ៤ ៥ ៣ ៤ ៥ អូយឃើញតែងាប់ស្មារទោស ហើយពេលវៀតណាមរំដោះណាកូនអាមនុស្សងាប់ចេះក៏ដល់ពេលវៀតណាមរំដោះទៅហ្វូងវារត់ទៅជាន់អាខ្មោចណឹងផងអាណាគ្នាមិនទាន់ងាប់ក៏នៅនោះឯង ជាន់ឡើងងាប់ មិនបាននៅរស់ទេខ្ញុំក៏រត់ចេញមកពីស្រែវិញហើយនៅនិងស្រែហើយណាកូនស្រូវដែលដឹកនិងរទេះទៅមិនជ្រុះស្រូវនិងកន្ទេលហា ម៉ែខ្ញុំទៅកើបយកម៉ែខ្ញុំប្រុងសម្លាប់ទេវតាជួយនេះ ស្រាប់តែឡាន ឡានយួនទៅដល់ អាស្លឹកឃើញអីគេស្រែកហូៗស្អីគេហៅស្អីទេ ទៅក៏ស្រែកក៏ម៉ែខ្ញុំវាព្រលែងមកវិញកុំអីវាយកទៅបាត់ហើយហើយអាស្វរតែស្រូវនោះច្រើនទៅប្រហែលប៉ុណ្ណេះឯង ប្រហែលមួយផ្ទិលចុះគាត់រស់បានដែលនៅកន្ទេលទៅដែលវានេះទៅពួកអ្នកដែលអ្នកដឹកនោះរលាស់ រលាស់ទៅនៅតាមក្រឡុកគន្លងរទេះទៅគាត់ទៅកើបបានមួយផ្ទិលគេចាប់ទៅ ទាញហើយបងខ្ញុំនោះអត់ហ៊ានទេ អត់ហ៊ានក្ររេក្រ៉ាៗបានតែអើតមើលយំទាំងអស់គ្នាបងជីដូនមួយ ហើយស្គាល់ៗអីនោះបានតែអូយស្រណោះយាយហាងដល់ហើយស្រណោះដល់ គេយកទៅហើយចេះគាត់នោះ ដើរទៅដើរមក អូនអើយឃើញឡានថ្នល់ជាតិណឹងឯងស្រាប់តែវារត់បាត់ទៅខ្ញុំនៅកណ្តាលគេហៅបឹងជីពួក គេហៅបឹងជីពួកណឹងគេទុកឲ្យគេរត់ពីកាលណា គេរត់យើងព្រឹកឡើងអត់ដឹងនៅតែ២នាក់ និយាយទៅនៅ២នាក់ប្អូនខ្ញុំអាកាំងហើយនិងកូនខ្ញុំកូននៅតូចកូនប្តីមុនខ្ញុំ ខ្ញុំជំនាន់អាពតខ្ញុំរៀបគ្រួសារទៅបានប្តីណឹង កើតកូនបានតែ៣ថ្ងៃទៅគេយកប្តីខ្ញុំទៅសម្លាប់ ប្តីសព្វថ្ងៃនេះប្តីក្រោយទេ ខ្ញុំកើតកូនបាន៣ថ្ងៃគេចាប់ទៅ គេចាប់ទៅថាយើងអីណាស័ក្តិ២ ស័ក្តិ៣ លាក់កាំភ្លើងលាក់អីទៅណា គេចាប់យកទៅណឹងកូនអូយខ្ញុំវេទនាខ្ញុំនិយាយប្រាប់នេះខ្ញុំមិនមែនថាចេះតែលាក់លៀមទេ មែនខ្ញុំប្រាប់ត្រង់ហើយខ្ញុំអត់កុហកទេ។

ក៖ បាទអ៊ុំ ចុះម្តាយរបស់អ៊ុំមានឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ឈ្មោះហាង ស្រស់ ហាង។

ក៖ បាទ ចុះឪពុកវិញ?

ខ៖ ឪពុកខ្ញុំឈ្មោះអ៊ី ខ្ញុំឪពុក២សួរឪពុកុយើងនៅសព្វថ្ងៃទៅមែនណាយើងឪពុកដែលថា យើងគាត់ចិញ្ចឹមយើងឪពុកចុង ឪពុកគាត់ឈ្មោះឈឹម គាត់ឈ្មោះគាន។

ក៖ ឈឹម គានណឹងឪពុកចុង?

ខ៖ ចាស។

កះ ឪពុកដើមចាំទេអ្នកមីង?

ខះ ឪពុកដើមខ្ញុំភ្លេចព្រោះដែលម៉ែខ្ញុំគាត់លែងគ្នានិងឪពុកខ្ញុំណឹងខ្ញុំកើតបានតែ៣ថ្ងៃទេ គាត់លែងគ្នា ឪពុកខ្ញុំទៅមានប្រពន្ធទៅម៉ែខ្ញុំគាត់ខឹងគាត់រត់មក មកនៅឯព្រែកទាល់នោះឯងទៅ ឪពុកខ្ញុំថាគាត់បានប្រពន្ធក្រោយមានកូនជម្លៀសទៅជម្លៀសមក មានចៅក្រោយទៀត ម៉ែខ្ញុំបានប្តីទៀតទៅគាត់ឪពុកចុងណឹងក៏គាត់ចិញ្ចឹមយើង មើលថែយើងដូចយើងជាកូនគាត់បង្កើតនោះឯង។

កះ ចុះម្តាយរបស់អ៊ុំជាមនុស្សបែបណាដែរអ៊ុំ? ជាមនុស្សកាច ឬក៏ស្លូតដែរ?

ខះ ម៉ែខ្ញុំបើនិយាយទៅនិងកូនចៅកាច កាចតែនិយាយទៅកាចកាចតែនិងខ្ញុំដែលប្អូនៗក្រោយអត់ តែខ្ញុំមួយវេទនាណាស់លោកអើយ ធ្វើបាបវាយក៏វាយ ជេរប្រចោរអាក្រក់គាត់ធ្វើបាបតែខ្ញុំណឹងឯងបានខ្ញុំនិយាយអីឡើងចង់តែយំខ្ញុំវេទនាណាស់ជីវិតខ្ញុំ ខ្ញុំម៉ែខ្ញុំអត់សូវស្រលាញ់ខ្ញុំទេ គាត់ស្រលាញ់តែកូនប្តីក្រោយធ្វើបាបខ្ញុំណាស់កូនអើយ ដូចថាពេលយើងធ្វើអីក៏មិនត្រូវធ្វើអីក៏មិនត្រូវកូនគាត់យកអីក៏អាកូនគាត់លួចដូចថាយករបស់អីស៊ីមានតែយើងណឹងឯងធ្វើបាបយើង វាយយើង ជេរយើង យើងធ្វើអីក៏មិនបានល្អនិងគេដែរ។

កះ ចុះម្តាយរបស់អ៊ុំណឹងគាត់មានស្រុកកំណើតនៅឯណាដែរអ៊ុំ?

ខះ ចាស គាត់អ្នកបាត់ដំបង និយាយទៅអ្នកអន្លង់តាម៉ិចំការស្វាយ។

កះ ចុះឪពុករបស់អ៊ុំវិញ។

ខះ ឪពុកខ្ញុំស្រុកកំណើតបើនិយាយទៅ នៅនិងនេះឯងឪពុកខ្ញុំដែលគាត់ចិញ្ចឹមខ្ញុំរាល់ដងណាគាត់នៅនេះឯងដីធ្លីអីមានតែគេដកអស់ហើយ។

កះ ចុះពួកគាត់ទាំងពីរណឹងមានមុខរបរជា ធ្វើអ្វីដែរអ៊ុំដើម្បីចិញ្ចឹមជីវិត?

ខះ កូនអើយពីដើមមិញវាយតែមោងចងសន្ទូចអីនោះឯង វាយមោងញឹកមោងអន្ទឹលអីទៅណា កាប់អុសប្រៀបមិនបានទេមុខរបរវាច្រើនកូនអ្នកទន្លេ ដូចថាយើងធ្វើអានេះមិនបានធ្វើអានោះធ្វើអានោះមិនបានចេះតែរកស៊ីចិញ្ចឹមកូនទៅចុះយើងអត់កូន យើងមិនបានមុខរបរដូចថាលបរាវ អួនអីអត់ដូចគេអត់មានយើងអត់មានទេយើងអ្នកក្រទៅ យើងមានតែមោងវាយ មោងបើក មោងញឹក កាប់អុស។

កះ បាទអ៊ុំ ចុះអ៊ុំនៅចាំជីដូនជីតាខាងម្តាយបានទេអ៊ុំ?

ខះ ចាំបានតើ។

កៈ ឈ្មោះអ្វីដែរអ៊ុំ?

ខៈ ម៉ាខ្ញុំឈ្មោះម៉ា ឃឹម តែតាឈ្មោះតាអ៊ុច តានេះខ្ញុំណា។

កៈ តាខាងម្ដាយណា?

ខៈ ចាស ទេតាខាងឪពុក បើតាខាងម្ដាយខ្ញុំមិនសូវចាំទេ គាត់នៅឯលើនោះឈប់សិន តាខាងម្ដាយឈ្មោះស្រស់ តែយាយឈ្មោះគួណឹងចាំមែននឹកឃើញហើយ ស្រស់ដែរដូចប្រសារក៏ស្រស់ឪពុកក្មេងក៏ស្រស់។

កៈ ចុះកាលអ៊ុំកើតមកណឹងអ៊ុំទាន់ពួកគាត់ទេ?

ខៈ អត់ទេខ្ញុំចាំខ្ញុំទាន់តែតាខ្ញុំឈ្មោះតាអ៊ុចណឹងខ្ញុំទាន់ បើយាយអីខូចអស់ហើយខាងណោះក៏ខូចខាងនេះក៏ខូច ខាងម្ដាយក៏ខូចខាងឪពុកក៏ខូចតែនៅតែតាអ៊ុចណឹងនៅខ្ញុំនៅកាលណឹងខ្ញុំទ្រើសដែរគ្រាន់ហើយប្រហែលអាយុ៣ ៤ឆ្នាំ ៥ឆ្នាំប៉ុនខ្ញុំចាំបាន។

កៈ ចុះអ៊ុំមានបងប្អូនឬក៏សាច់ញាតិណាដែលរស់នៅក្រៅប្រទេសទេអ៊ុំ?

ខៈ អត់ទេកូន ។

កៈ បាទ ចុះស្វាមីរបស់អ៊ុំមានឈ្មោះអ្វីដែរអ៊ុំ?

ខៈ ឈ្មោះស៊ុន ផុន។

កៈ សព្វថ្ងៃណឹងមែនទេអ៊ុំ?

ខៈ ចាសសព្វថ្ងៃ។

កៈ បាទអ៊ុំ ចុះអ៊ុំបានស្គាល់គ្នាដោយរបៀបណាដែរ បានយកគ្នាជាប្ដីប្រពន្ធណឹងអ៊ុំ?

ខៈ និយាយទៅជំនាន់ណឹងខ្ញុំនៅព្រែកទាល់គាត់អ្នកដំដែកនេះទេ តែគាត់សឹកពីបួសទៅមិនដឹងយ៉ាងម៉េចមួយហ៊ីគេរកពស់នោះអាកូន គេទៅក៏ឃើញខ្ញុំមេម៉ាយគេកម្លោះទេ ទៅដល់គាត់មកណឹង គាត់មករកត្រីនៅខាងគេហៅព្រែកដាខ្ញុំនៅឯព្រែកទាល់នេះទេ ដល់គាត់ស្គាល់ប្អូនថ្លៃខ្ញុំគាត់សុំប្អូនថ្លៃខ្ញុំមកលេង មកលេងទៅឃើញខ្ញុំប៉ុន្ដែមុនដំបូងគាត់មិនស្គាល់ខ្ញុំគាត់មិនស្រលាញ់ខ្ញុំទេប្អូនខ្ញុំជីដូនមួយ ទៅក៏គេស្រលាញ់គ្នាឯនោះទៅខ្ញុំអត់ដឹងអីទេ ខ្ញុំហៅអន្ទិតគេហៅខ្ញុំអត់ស្គាល់ឈ្មោះគេមុនដំបូង លឺគេហៅ អន្ទិតៗក៏អន្ទិតណឹងគេដែរអន្ទិតៗទៅ អន្ទិតអើយអូនចេះចុះទៅបានដឹងយ៉ាងម៉េចអីយ៉ាងម៉េចប្អូនខ្ញុំនោះគេស្រលាញ់គ្នាអ្នកផ្សេងទៅបានគ្នាអ្នកផ្សេងទៅគាត់មកសំពះសុំខ្ញុំ ទាន៥ បារី៥ ធូប៥ ផ្កា៥ ស្រាមួយដប បារីមួយកញ្ចប់ទៅគាត់សុំម៉ែខ្ញុំទៅម៉ែខ្ញុំគាត់ឲ្យទៅ។

កៈ បាទចុះអ៊ុំហេតុអីក៏ជ្រើសរើសយកគាត់ធ្វើជាស្វាមីដែរអញ្ចឹងអ៊ុំ?

ខៈ ម្ដាយគាត់ឲ្យហើយ ញាតិអ្នកស្រុកគេថាដែរថាយើងស្គាល់ ប៉ុន្ដែខ្ញុំប្រថុយទៅវាវេទនាខ្ញុំនៅជាមួយម៉ែបងប្អូនក៏ពិបាកម៉េចបានខ្ញុំថាអញ្ចឹងព្រោះគាត់កូនគាត់ក្រោយគាត់ស្រលាញ់តែខ្ញុំគាត់មិនស្រលាញ់ទេព្រោះយើងម៉េមាយផងកូនគាត់អត់ទាន់មានប្ដីទាំងអស់ខ្ញុំនៅទៅស៊ីបាយក៏គេថាខ្ញុំដួលលាក់ អាធ្វើអីគេប្រាប់ម៉ែថាខ្ញុំដួសលាក់ អាមិនបានសោះមិនបានធ្វើសោះក៏គេនិយាយថាយើងទៅពួនស៊ីបាយក្នុងព្រៃ អ៊ុំទូកទៅស៊ីបាយតែការពិតអត់ យើងមិនដែលបានស៊ីអីទេប៉ុន្ដែគាត់ប្អូនៗខ្ញុំវាប្រាប់ម៉ែខ្ញុំទៅម៉ែខ្ញុំចេះតែរករឿងខ្ញុំទៅខ្ញុំខ្ចិលដល់គាត់ឲ្យហើយខ្ញុំយកប្រសិនខ្ញុំប្រថុយទៅថា ខ្ញុំវាត្រូវគេធ្វើបាបធ្វើអីមិនដឹងធ្វើម៉េច ខ្ញុំបានទៅក៏គាត់មិនដែលបានវាយខ្ញុំទេ មិនដែលវាយទេក៏យើង។

កៈ ចុះពីក្មេងអ៊ុំបានទៅរៀនទេអ៊ុំ?

ខៈ អត់ទេកូនអើយ នៅនេះឯងតែខ្ញុំនៅពីតូចឲ្យទៅរៀនកាលនោះទៅនៅសាលាស្អីម៉ាស៊ីនកិនថ្ម ដល់ពេលទៅរៀនទៅអាល័យតែមើលប្អូន ម៉ែគាត់ប្រើគាត់បានប្ដីក្រោយគាត់មានកូនគាត់ឲ្យមើលប្អូនផងអាណាធ្វើប្រហុកតូចប៉ុននេះ គ្រវែងចោលខ្លះធ្វើខ្លះទៅគាត់វាយគាត់អីខ្ជិលខ្ញុំ រំពាត់ខ្ញុំអត់រៀនធ្វើបាបខ្ញុំពេកទៅដើរឡើងបេះផ្លែពរភ្លាបានបងខ្ញុំជីដូនមួយ ពេលអញទៅវិញអញប្រាប់មីងថាង៉ែងរៀនហើយង៉ែងបេះផ្លែពរភ្លាឲ្យអញណា ចាស បេះឲ្យគេទៅក៏ចេះតែចឹងអត់បានរៀនទៅ ដូចថារៀនក៏មិនបានជាប់កូនមិនមែននៅមួយកន្លែងទេដូចថាយើងអត់ទៅយើងទៅរកស៊ី។

កៈ ចុះអ៊ុំចេះអាន និងចេះសរសេរអក្សរខ្មែរទេសព្វថ្ងៃណឹង?

ខៈ ទេមិនចេះអី តែលេខក៏មិនចេះ អក្សរក៏មិនចេះអត់ទាំងអស់។

កៈ ចុះអ៊ុំមានមិត្តភិក្តដែលស្និស្នាលធំធាត់មកជាមួយគ្នាតាំងពីក្មេងដល់ឥឡូវមានទេអ៊ុំ?

ខៈ អត់មានបើនិយាយទៅមានប៉ុន្ដែគេបែកគ្នាអស់ហើយមិនដឹងគេទៅដល់ណាអីអស់ហើយ។

កៈ ចុះតាំងពីក្មេងមកដល់ពេលនេះតើអ៊ុំធ្លាប់ប្រកបការងារអ្វីខ្លះដែរអ៊ុំដើម្បីចិញ្ចឹមជិវិត និងគ្រួសារដែរអ៊ុំ?

ខៈ ខ្ញុំកាលនៅនេះអីខ្ញុំវាយមោងអីតូចអីទៅណា ទៅវាយក្រៅអី ទៅហើយខ្ញុំវាយមោងប្ដីខ្ញុំវាយមោងវាយអី ទៅដល់ពេលខ្ញុំទៅនៅអាស្រែកណ្ដាលដំបងនោះវិញទៅប្ដីខ្ញុំគេហៅឲ្យធ្វើកម្មករក៏ចេះតែធ្វើជាប់ទៅ។

កៈ ចុះអ៊ុំអត់ធ្លាប់ប្រកបអាជីវកម្មលក្ខណៈ ដូចជាចិញ្ចឹមគោ ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់អីធ្លាប់ទេអ៊ុំ?

ខ៖ ធ្លាប់ដែលខ្ញុំមកនេះឯងដែលអាមួយហ៊ីយើងគេស្ទីអង្ករអីទេគេឲ្យជ្រូកចិញ្ចឹមនោះខ្ញុំធ្លាប់ចិញ្ចឹមឲ្យជ្រូកតែគេអត់បានឲ្យមាន់ទេប៉ុនខ្ញុំទិញចិញ្ចឹមខ្លួនឯងខ្ញុំបានគេឲ្យកង់មួយគេថតដែរណឹង ខ្ញុំដូចពេលយើងចិញ្ចឹមទៅយើងបានធំទៅគេថតយើងថាយើងលក់ទៅយើងបានអីថាបានកង់ខ្ញុំបានកង់ទៅវាថតតែតាំងពីកូនខ្ញុំនៅតូចៗម្ល៉េះ។

ក៖ តាំងពីក្មេងដល់ពេលនេះជីវិតអ៊ុំមានការផ្លាស់ប្តូរអ្វីខ្លះដែរអ៊ុំ?

ខ៖ វាគ្រាន់ដែលឥឡូវនេះឯងទើបមានអាឡូវនេះប៉ុន្តែវាមិនមានឲ្យថាមានអីបរបូណ៌ទេណាកូនចុះកម្មករគាត់ចាស់ហើយមានដូចថាទៅរកឯណាបានធំដុំនិងគេ បើជូនកាលទៅក៏បាន២ម៉ឺនទៅ យប់បាន២ម៉ឺន ថ្ងៃទៅជូនកាលបាន២ម៉ឺន ជូនកាលបាន១៥០០០អីទៅ បើស្រេចតែមានត្រីបើអត់មានត្រីក៏យើងអត់មានអីសែង។

ក៖ ចុះកាលពីនៅក្មេងអ៊ុំធ្លាប់មានក្តីស្រម៉ៃថាធំឡើងចង់ធ្វើអ្វីទេអ៊ុំ?

ខ៖ ចង់បាន ចង់មាន ចង់ឃើញគេមានផ្ទះធំ ចង់ឃើញគេដូចថា គេច្រៀងគេអីមិនដឹងគេធ្វើយ៉ាងម៉េចបានគេទៅច្រៀងបាន អញប្រសិនជាច្រៀងនិងគេអីអញច្រៀង អញច្រៀងដូចថាឲ្យជាប់និងគេចេះតែនឹកឃើញទៅណា ហើយអញបានទៅអញធ្វើផ្ទះចង់បានផ្ទះឲ្យមួយឲ្យស្អាតនិងគេ តែមានតែផ្ទះបំបោស។

ក៖ ចឹងទាក់ទងជាមួយចំណង់ចំូលចិត្តអ៊ុំម្តង តាំងពីក្មេងដល់ឥឡូវអ៊ុំចូលចិត្តម្ហូបណាជាងគេដែរអ៊ុំ? សម្លរណាជាងគេដែរចូលចិត្តហូប?

ខ៖ ខ្ញុំនិយាយទៅទឹកគ្រឿង។

ក៖ ចូលចិត្តទឹកគ្រឿង?

ខ៖ ណឹងហើយ ចាសចូលចិត្តតែទឹកគ្រឿង ហើយត្រីអាំងអីប៉ុណ្ណឹងឯង បើចូលចិត្តជាងគេមានតែទឹកគ្រឿងណឹងឯង។

ក៖ បាទអ៊ុំ ចុះអ៊ុំចូលចិត្តស្តាប់បទចម្រៀងទេកាលពីក្មេង?

ខ៖ អូ! ពូកែហើយខ្លាំង សូម្បីតែសព្វថ្ងៃក៏ដោយគេធុញគ្រប់គ្នាប៉ុន្តែញាក់ញ័រអីអត់ទេចូលចិត្តតែចម្រៀងណាកំសត់ៗ ហើយបើមើលតាមយូធូបអីបើឃើញថាគេកំសត់អីក៏យំរ៉ល់ល្ងាចចឹងឯងភ្នែកដង្ហើមចឹងឯងព្រោះធ្លាប់ខ្លួនឯងវាវេទនានោះកូន ឃើញគេបង្ហោះទៅដែលថាមានតែបងប្អូន២នាក់ទៅតាំងពីម៉ែទៅចោលនឹងតាំងពីកូនអាយុ៨ឆ្នាំ អាបង៨ឆ្នាំមីស្រីនោះមិនដឹងប៉ុណ្ណាហើយរស់ខ្ញុំយំអើយយំ នឹកឃើញយំស្រណោះគេណាស់។

ក៖ ចុះអ៊ុំចេះលេងឧបករណ៍តន្រ្តីអ្វីទេអ៊ុំ?

ខ៖ អត់ទេកូនអត់ចេះទេ។

ក៖ ចូលចិត្តតែច្រៀង?

ខ៖ ចាស ច្រៀងណឹងខ្ញុំមិនដែលច្រៀងខ្លួនឯងដូចថាស្ដាប់គេទៅបើកូនច្រៀងអីសប្បាយចិត្ត ហើយអត់មានជំទាស់ថា កូនកុំច្រៀងអី វាថ្លង់វាអត់ខ្ញុំអត់ទេឲ្យតែច្រៀងពិរោះគឺចូលចិត្តហើយ អ្នកណាក៏ដោយកុំឲ្យថាកូនថាអីអ្នកក្រៅអីក៏ដោយឲ្យតែមកផ្ទះខ្ញុំចូលចិត្តណាស់ ដូចថាគេ ច្រៀងពិរោះអី។

ក៖ ចឹងមកដល់សព្វថ្ងៃណឹងអ៊ុំមានកូន និងចៅប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ កូនខ្ញុំរាប់ភ្លេចថើហើយខ្ញុំមីទី១នោះ៧ អាទី២នោះ៤ មីទី២ ៤ ៨ និង៧?

ក៖ ១៥។

ខ៖ ១៥មីពៅគេនោះ៣ ។

ក៖ បាទអីយ៉ាងច្រើនគួរសមដែរ បាទអញ្ចឹងចុងបញ្ចប់នេះតើអ៊ុំមានអ្វីចង់ផ្ដាំផ្ញើទៅកាន់កូនចៅ ជំនាន់ក្រោយ ឬក៏ទូន្មានពួកគាត់ទេថា ពួកគាត់គួរតែរស់នៅបែបបណា ឬក៏ធ្វើជាមនុស្សបែប ណាក្នុងសង្គមដែរអ៊ុំ?

ខ៖ ចាស ខ្ញុំសូមផ្ដាំទៅបងប្អូនប្រជាពលរដ្ឋនៅប្រទេសខ្មែរក៏ដោយ ប្រទេសឯណាក៏ដោយ សូមធ្វើពលរដ្ឋល្អ សុំកូនចៅក្មេងៗអីកុំ និយាយទៅគ្រឿងញៀនគ្រឿងអីជៀសឲ្យឆ្ងាយហើយ កុំធ្វើ ព្រោះសម័យអាពតវេទនាណាស់ ខ្លាចវិលទៅវិញគឺវេទនាខ្លាំងណាស់ កុំឲ្យសោះកូនចៅ ទាំងអស់គ្នា កុំប្រព្រឹត្តអារឿងអញ្ចឹងឲ្យសោះ ខ្លាចណាស់ខ្ញុំ ខ្លាច។

ក៖ បាទអ៊ុំ អញ្ចឹងខ្ញុំសូមអរគុណដល់អ៊ុំដែលបានចំណាយពេលវេលាសម្ភាន៍ជាមួយខ្ញុំអ៊ុំណា ចឹងខ្ញុំសូមជូនពរឲ្យមានសុខភាពល្អ មានសំណាងល្អ និងមានសុភមង្គលក្នុងក្រុមគ្រួសារអ៊ុំ ណា។

ខ៖ ចាស ចាស។